**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ...៧៩២.ស.ជ.ណ.ប.ស្ល

# សេចក្ដីប្រកាសព័ត៌មាន
## អត្រានៃការបាត់បង់គម្របព្រៃឈើនៅកម្ពុជាមានការធ្លាក់ចុះ

ក្រសួងបរិស្ថានមានការសោកស្ដាយយ៉ាងខ្លាំង ដែលនៅប៉ុន្មានថ្ងៃនេះ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិព្រមទាំងប្រព័ន្ធផ្សព្វផ្សាយមួយចំនួន បាននិងកំពុងតែបំភ្លៃ បំផ្លើស និងបំភ័ន្តមតិសាធារណៈអំពីស្ថានភាពធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបានបំប៉ោងទិន្នន័យនៃបទល្មើសព្រៃឈើ និងការនាំចេញឈើទៅក្រៅប្រទេសដែលមានលក្ខណៈញុះញង់ និងមានចេតនាមួលបង្កាច់រាជរដ្ឋាភិបាល និងទាត់ចោលកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាលើការការពារ និងអភិរក្សធនធានធម្មជាតិ។ ប្រព័ន្ធផ្សព្វផ្សាយបរទេសមួយចំនួន និងសង្គមស៊ីវិលជាតិ-អន្តរជាតិខ្លះបាននឹងកំពុងបំពេញការងារនៅកម្ពុជាជាមួយនឹងរបៀបវារៈនយោបាយមួយដោយមានការចាត់តាំងច្បាស់លាស់ ហើយមិនបានបម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជនកម្ពុជាឡើយ។ ក្រសួងបរិស្ថាន សូមគូសបញ្ជាក់ថា បទល្មើសព្រៃឈើទ្រង់ទ្រាយធំ លែងកើតមានទៀតហើយនៅក្នុងប្រទេសកម្ពុជា ហើយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា កំពុងបន្តទប់ស្កាត់ និងលុបបំបាត់បទល្មើស ព្រៃឈើទ្រង់ទ្រាយមធ្យម និងតូច និងពង្រឹងកិច្ចការពារ និងគ្រប់គ្រងធនធានធម្មជាតិឱ្យបានកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ជាមួយគ្នានេះ ក្រសួងបរិស្ថានក៏សូមជម្រាបជូនថា យោងតាមទិន្នន័យបម្រែបម្រួលគម្របព្រៃឈើនៃប្រព័ន្ធតំបន់ការពារធម្មជាតិឆ្នាំ ២០១០-២០១៤ រៀបចំដោយអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន បង្ហាញឱ្យឃើញថាមានអត្រាបាត់បង់ជាមធ្យមប្រចាំឆ្នាំប្រមាណ ០,៦២ % នឹងក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះក្នុងឆ្នាំ ២០១៤-២០១៦ អាត្រានៃការបាត់បង់គម្របព្រៃឈើប្រចាំឆ្នាំបានធ្លាក់ចុះមកនៅកម្រិត០,៣%។ សូមជម្រាបថា លទ្ធផលបឋមនៃការវាយតម្លៃគម្របធនធានព្រៃឈើកម្ពុជាឆ្នាំ ២០១៦ បានបង្ហាញថាផ្ទៃដីគម្របព្រៃឈើសរុបនៅកម្ពុជា មានចំនួនប្រមាណ ៤៥,២៦% ធៀបនឹងផ្ទៃដីប្រទេស ។ អត្រានៃការបាត់បង់គម្របព្រៃឈើនៅកម្ពុជា ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះមានការធ្លាក់ចុះដោយចន្លោះពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៦ អាត្រានៃការបាត់បង់គម្របព្រៃឈើមានចំនួន ០,៩២% ខណៈចន្លោះឆ្នាំ២០១០-២០១៤ អាត្រានៃការបាត់បង់គម្របព្រៃឈើមានប្រមាណ ២,៧%ក្នុងមួយឆ្នាំ។

អត្រាថយចុះគួរឱ្យកត់សម្គាល់នៃការបាត់បង់គម្របព្រៃឈើនេះគឺដោយសារតែប្រសិទ្ធភាពនៃការអនុវត្តកំណែទម្រង់លើការការពារ និងគ្រប់គ្រងធនធានធម្មជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ការដាំព្រៃឈើឡើងវិញនៅតំបន់របោលមួយចំនួន ក៏ដូចជាការចូលរួមពីសហគមន៍មូលដ្ឋាន កម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ និងបង្ក្រាបលើបទល្មើសព្រៃឈើ។ ក្រសួងបរិស្ថាននឹងបន្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនក៏ដូចជាសហការជាមួយស្ថាប័ន ដៃគូអភិវឌ្ឍន៍ ភាគីពាក់ព័ន្ធនានាក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ អភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាពដើម្បីនិរន្តរភាព បរិស្ថាន និងធនធានធម្មជាតិ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា ឆ្នាំ ២០១៧